ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៣ ព្រទ.ស.ច-៩៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរ

## នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោក ប្រធានតុលាការកំពូល**
**លោក អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**
**លោក ប្រធានសាលាឧទ្ធរណ៍**
**លោក ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**
**លោក ប្រធានតុលាការខេត្ត ក្រុង**
**លោក ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**
**លោក ប្រធានតុលាការយោធា**
**លោកព្រះរាជអជ្ញាអមតុលាការយោធា**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ ឬទៅតុលាការកំពូល ។

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា គ្រប់តុលាការខេត្ត ក្រុង ជាពិសេសតុលាការរាជធានីភ្នំពេញមិនបានបំពេញភារកិច្ចរបស់ខ្លួន តាមការណែនាំក្នុងសារាចរលេខ ០៨/ សរ ៩៣ ចុះថ្ងៃទី២០ សីហា ១៩៩៣ ដែលមានចម្លងជូនជាប់មកជាមួយនេះទេ ។

ក្រឡាបញ្ជីភាគច្រើនបង្កប់ទុកសំណុំរឿងរបស់គេច្រើនខែ មិនព្រមផ្ញើពីតុលាការខេត្ត-ក្រុង ទៅសាលាឧទ្ធរណ៍ ឬពីសាលាឧទ្ធរណ៍ទៅតុលាការកំពូលឱ្យបានឆាប់ឡើយ ។ ប្រជាជនបានប្តឹងមកក្រសួងយុត្តិធម៌ច្រើនអំពីរឿងនេះ ។

ខ្ញុំសូមអស់លោកអានឡើងវិញនូវចំណុច៣ ទំព័រទី២ នៃសារាចរខាងលើនេះ ដែលចែងអំពីការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ ឬទៅតុលាការកំពូល ក្នុងនោះក្រសួងបានដាក់កំហិតឱ្យបញ្ជូនក្នុងរយៈពេល១ខែយ៉ាងយូរ ។

ចាប់ពីថ្ងៃនេះតទៅ បើសំណុំរឿងដែលត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ឬបញ្ជូនទៅតុលាការកំពូលមិនអនុវត្តក្នុងរយៈពេលកំណត់ ១ ខែនេះទេ នោះលោកប្រធានតុលាការត្រូវទទួលការព្រមាន ហើយក្រឡាបញ្ជីដែលទទួលភារកិច្ចចាត់ចែងបញ្ជូនសំណុំរឿងនឹងត្រូវទទួលវិន័យដកចេញពីតុលាការ ។

ខ្ញុំសូមអស់លោកយកចិត្តទុកដាក់ខ្ពស់ចំពោះសារាចរ និងចំពោះវិធានការណ៍ដែលក្រសួងបានកំណត់មិនអាចអត់អោនឱ្យបានឡើយ ។

ទទួលបានសារាចរនេះ ខ្ញុំសូមអស់លោកធ្វើការប្រជុំផ្សព្វផ្សាយជាបន្ទាន់ក្នុងតុលាការ ហើយថតចម្លងសារាចរនេះផ្តល់អោយក្រឡាបញ្ជី ១ច្បាប់ម្នាក់គ្រប់ៗគ្នា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
( ព្រះរាជាធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម )
-សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ